BBI0074

សម្ភាសជាមួយឈ្មោះ ប៉ុក សេងហាន ភេទ ស្រី អាយុ ៦០ឆ្នាំ

មុខងារខ្មែរក្រហមៈ ធ្វើស្រែ

មុខងារបច្ចុប្បន្នៈ ធ្វើស្រែចំការ

មានស្រុកកំណើតនៅៈ ភូមិពងទឹក ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅភូមិស្វាយជ្រុំ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ ស សេងគា

០០:៣១:៤៧

ទំព័រ១៦

សេងគា : បាទ!ខ្ញុំម៉ោផ្ទះអ៊ំនេះខ្ញុំចង់សម្ភាសន៍អ៊ំពីរឿងរ៉ាវរបស់អ៊ំផ្ទាល់ខ្លួនរបស់អ៊ំ បាទអ៊ំឆ្លើយបានប៉ុណ្ណាយកប៉ុនហ្នឹងអ៊ំ ខ្វាចអ៊ំ បើអ៊ំចាំក៏ឆ្លើយ បើភ្លេចប្រាប់ថាភ្លេចចុះអត់អីទេ ខ្ញុំឈ្មោះ សេងគាម៉ោពីអង្គការមជ្ឈមណ្ឌលកម្ពុជា ចងក្រងឯកសារចាស់ជំនាន់មុនៗដូចជាអ៊ំអីអញ្ចឹងដែលបានឆ្លងកាត់ពីជំនាន់ហ្នឹងទៅ អញ្ចឹងក៏ចង់ដឹងអំពីរឿងរ៉ាវហ្នឹងដើម្បីយកទៅចងក្រងហ្នឹង ហើយក៏យករឿងរបស់អ៊ំសរសេរជាឯកសារ ដើម្បីប្រើប្រាស់អីអញ្ចឹងអត់មានពាក់ព័ន្ធរឿងនយោបាយទេ អញ្ចឹងអ៊ំអត់ថាអីទេអ៊ំ?

ហាន : ចា៎!

សេងគា : បាទ!អញ្ចឹងអ៊ំឈ្មោះអីអ៊ំ?

ហាន : ហានៗ

សេងគា : ឈ្មោះអី ហាន?

ហាន : ប៉ុក សេងហានៗ

សេងគា : ប៉ុក សេងហាន?

ហាន : ចា៎!

សេងគា : អ៊ំអាយុប៉ុន្មានហើយអ៊ំ?

ហាន : ៥៥ឆ្នាំៗ

សេងគា : សព្វថ្ងៃធ្វើអីដែរអ៊ំ?

ហាន ៖ ធ្វើស្រែ ។

សេង៍គា ៖ អ៊ីស្រុកកំណើតនៅណាដែរអ៊ី?

ហាន ៖ ស្រុកកំណើតខ្ញុំនៅកណ្តាល ។

សេង៍គា ៖ ភូមិអីដែរអ៊ី?

ហាន ៖ គេហៅភូមិទន្លា ឃុំកន្ទួត ។

សេង៍គា ៖ ស្រុកកណ្តាលស្ទឹងអ៊ី?

ហាន ៖ ចាំ!

សេង៍គា ៖ ខេត្តកណ្តាល បច្ចុប្បន្នអ៊ីរស់នៅភូមិ នៅភូមិនេះភូមិស្វាយជ្រុំអ៊ី?

ហាន ៖ ចាំ!នៅស្វាយជ្រុំ ។

សេង៍គា ៖ ឃុំអូរដារអ៊ី?

ហាន ៖ ចាំ!

សេង៍គា ៖ ស្រុកកំរៀង ខេត្តបាត់ដំបងអ៊ី?

ហាន ៖ ចាំ!

សេង៍គា ៖ ឪពុកអ៊ីឈ្មោះអីដែលអ៊ី?

ហាន ៖ ឪពុកខ្ញុំឈ្មោះ ប៊ុល ប៊ុក ។

សេង៍គា ៖ ពីមុនគាត់ធ្វើអីអ៊ី?

ហាន ៖ ធ្វើស្រែ?

សេង៍គា ៖ ឥឡូវគាត់ស្លាប់ហើយអ៊ី?

ហាន ៖ ចាំ!

សេង៍គា ៖ ស្លាប់ពីពេលណាម៉ោអ៊ី?

ហាន ៖ យូរហើយតាំងពីខ្ញុំនៅតូចៗ ។

សេង៍គា ៖ អ្ហូ!តាំងពីជំនាន់៦០ជាង៍អ៊ី?

ហាន ៖ ចាំ!តាំងពីខ្ញុំអាយុ១០ឆ្នាំ ។

សេង៍គា ៖ ចុះម្តាយអ៊ី?

ហាន ៖ ម៉ែខ្ញុំគាត់ទឹមស្លាប់ឥឡូវដែរ ។

សេង៍គា ៖ ម្តាយឈ្មោះអីអ៊ី?

ហាន ៖ ហ៊ុង៍ ។

សេងគា ៖ ឈ្មោះអីហុង?

ហាន ៖ ទុយ ហុង ឪពុកគាត់ឈ្មោះទុយ ។

សេងគា ៖ ម្ដាយស្លាប់ប៉ុន្មានឆ្នាំហើយអ៊ំ?

ហាន ៖ គាត់ស្លាប់៣ឆ្នាំនេះទេ ។

សេងគា ៖ អ៊ំមានបងប្អូនប៉ុន្មាននាក់អ៊ំ?

ហាន ៖ ខ្ញុំមានបងប្អូន២នាក់ ។

សេងគា ៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មានអ៊ំ?

ហាន ៖ ស្រីដូចគ្នាទាំងពីរហ្នឹង ។

សេងគា ៖ អ៊ំបងគេ ឬប្អូន?

ហាន ៖ ខ្ញុំបង ។

សេងគា ៖ អ៊ំប្ដីឈ្មោះអីដែលអ៊ំ?

ហាន ៖ ឈ្មោះ ថន ។

សេងគា ៖ ប្ដីអីធនអ៊ំ?

ហាន ៖ ទិន ប៊ុនថន ។

សេងគា ៖ គាត់អាយុប៉ុន្មានហើយឥឡូវ?

ហាន ៖ អាយុ៦០ឆ្នាំ ។

សេងគា ៖ គាត់ធ្វើអីដែររាល់ថ្ងៃ?

ហាន ៖ ធ្វើស្រែចំការ ។

សេងគា ៖ ចុះកាលពីមុនគាត់ធ្វើអី?

ហាន ៖ កាលពីមុនជាគ្រូបង្រៀនក្មេង ។

សេងគា ៖ អូ!ជាគ្រូបង្រៀនអ៊ំ?

ហាន ៖ ចា៎!

សេងគា ៖ ឥឡូវគាត់ឈប់ហើយ រឺត្រែតហើយអ៊ំ?

ហាន ៖ ឈប់ហើយ ឈប់ប្រហែលជាង១០ឆ្នាំ ។

សេងគា ៖ បង្រៀនខាងអីគេអ៊ំ បង្រៀនអក្សរខ្មែរយើង?

ហាន ៖ អក្សរខ្មែរយើង ។

សេងគា ៖ អ៊ំមានបងប្អូនអ៊ីស្លាមដែរមែន?

ហាន ៖ 	អត់ទេ!ខ្មែរសុទ្ធ ។

សេង៉គា ៖ ខ្មែរសុទ្ធ ខ្ញុំស្មានតែខ្មែរអ៊ីស្លាម ប្ដីអ៊ំកាលពីសម័យមុនគាត់ធ្វើអី គាត់ធ្វើកងទ័ពដែរឬ ម៉េច?

ហាន ៖ 	អត់ទេ ។

សេង៉គា ៖ អ្នករត់គេចខ្លួនដែរ កងយុវជនអីធម្មតា?

ហាន ៖ 	ចា៎!

សេង៉គា ៖ អ៊ំមានកូនប៉ុន្មាននាក់អ៊ំ?

ហាន ៖ 	ខ្ញុំ៩នាក់ ។

សេង៉គា ៖ កូន៩នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មានអ៊ំ?

ហាន ៖ 	ប្រុស៦នាក់ ស្រី៣នាក់ ។

សេង៉គា ៖ មានស្លាប់អត់ទេកូន?

ហាន ៖ 	ស្លាប់១នាក់ ។

សេង៉គា ៖ ស្លាប់កូនទីប៉ុន្មាន?

ហាន ៖ 	ទីប៉ុន្មានហើយទេ ទី៦ទី៧ទេ ។

សេង៉គា ៖ អញ្ចឹង!មានចាំឈ្មោះកូនទាំងអស់ទេអ៊ំ?

ហាន ៖ 	ចា៎!ចាំ ។

សេង៉គា ៖ កូនទី១ឈ្មោះអីអ៊ំ?

ហាន ៖ 	កូនទី១ឈ្មោះ ថៃ ស៊ីធឿន ។

សេង៉គា ៖ ទី២?

ហាន ៖ 	ទី២ ថៃស៊ីនីម ។

សេង៉គា ៖ ទី៣អ៊ំ?

ហាន ៖ 	ទី៣ ថៃ សារ៉េន ។

សេង៉គា ៖ ទី៤?

ហាន ៖ 	ទី៤ថៃ សារ៉ុត ។

សេង៉គា ៖ ទី៥អ៊ំ?

ហាន ៖ 	ថៃ សារ៉ា ។

សេង៉គា ៖ ទី៦?

ហាន ៖ ថៃ វណ្ណា ។

សេងគា ៖ ទី៧?

ហាន ៖ ភ៉ាន់ដា ។

សេងគា ៖ ទី៨អ៊ី?

ហាន ៖ ថៃ ធារី ។

សេងគា ៖ ទី៩?

ហាន ៖ ថៃ ប៊ូលី ។

សេងគា ៖ គាត់ស្លាប់ឈ្មោះអីអ៊ី?

ហាន ៖ ឈ្មោះ ភ៉ាន់ឌី ។

សេងគា ៖ អ្ហូ!អីអញ្ចឹងមានតែ១០នាក់អ៊ី?

ហាន ៖ ចាំ!១០នាក់ ។

សេងគា ៖ ភ៉ាន់ឌី ហ្នឹងកូនទីប៉ុន្មានហើយ ។

ហាន ៖ កូនទី៧ហើយ ។

សេងគា ៖ អញ្ចឹងបន្ទាប់ពីភ៉ាន់ដា?

ហាន ៖ ហ្នឹងហើយបន្ទាប់ពីភ៉ាន់ដា ព្រោះ២នាក់ហ្នឹងភ្លោះដាក់ភ៉ាន់ដា ភ៉ាន់ឌី ដល់ពេលស្លាប់ ទៅ ។

សេងគា ៖ អ្ហូ!ភ្លោះអ៊ី?

ហាន ៖ ចាំ!ភ៉ាន់ដាហ្នឹងបង ប្អូនស្លាប់ហើយ ។

សេងគា ៖ កាលហ្នឹងស្លាប់សម័យណាអ៊ី?

ហាន ៖ យូរដែលហើយ ។

សេងគា ៖ សម័យខ្មែរក្រហមឬក៏ម៉េច ឬក៏ឥឡូវៗហ្នឹងទេប្រហែល៩០ជាងនេះទេ?

ហាន ៖ ដាច់ៗហើយ ។

សេងគា ៖ អ្ហូ!ដាច់ហើយ?

ហាន ៖ ចាំ!

សេងគា ៖ ស្លាប់ដោយសារអីអ៊ីបានស្លាប់?

ហាន ៖ វាក្តៅតែមួយយប់ បានអាយុទឹម៩ខែ ។

សេងគា ៖ បាទ!ខ្ញុំចង់សួររឿងរ៉ាវទាក់ទងពីអ៊ំ កាលមុននៅកន្ទួតខេត្តកណ្ដាល អញ្ចឹងកាលពីអ៊ំនៅពី តូចបានរៀនបានសូត្រទេអ៊ំ?

ហាន : ខ្ញុំរៀនបាន២ឆ្នាំ ប៉ុនកាលហ្នឹងជំនាន់ហ្នឹងរៀនព្រឹកល្ងាច ខ្ញុំមើលសៀវភៅកុមារ កាលហ្នឹងគេហៅសៀវភៅកុមាររដ្ឋាន ។

សេងគា : អ៊ំមើលសៀវភៅដាច់?

ហាន : ចា៎! មើលដាច់ ។

សេងគា : ហើយម៉េចបានឈប់អ៊ំ?

ហាន : ឈប់កាលហ្នឹងម៉ែខ្ញុំឪពុករវល់តែលែងគ្នា ដីលែងគ្នាពុកខ្ញុំរកយកខ្ញុំទៅ ខ្ញុំអត់ព្រមទៅ អត់ព្រមទៅគាត់ថាបើមិនទៅទេ គាត់ទៅចាប់នៅសាលារៀន ខ្ញុំឈប់រៀនរហូតខ្លាចគាត់ទៅចាប់ ។

សេងគា : ខ្លាចឪពុកចាប់ក៏ឈប់រៀនទៅ?

ហាន : ចា៎!

សេងគា : ហើយឪពុកមានម៉ោយកទៅទេ?

ហាន : អត់ទេ គាត់គ្រាន់តែថាអញ្ជឹង ប៉ុនគាត់ទិញខោអាវទិញស្អីៗផ្ញើរម៉ោរហូត ប៉ុនគាត់ថាបើមិនទៅតាមគាត់ គាត់ចាប់ ។

សេងគា : ហើយគាត់ទៅណាទៅ?

ហាន : ឮថានៅស្រុកក្បែរគ្នា នៅខ្មែននៅអីណា ។

សេងគា : អ្ហូ!

ហាន : ហើយខ្ញុំនៅតូចខ្ញុំខ្លាច ។

សេងគា : ហើយក៏ឈប់ទៅរៀនទៅ?

ហាន : ចា៎! អាយុ៨ឆ្នាំខ្លាចអត់ហានទៅសាលា ។

សេងគា : អញ្ជឹងចូលរៀនតាំងពីអាយុប៉ុន្មានអញ្ជឹង?

ហាន : អាយុ៨ឆ្នាំហ្នឹង ។

សេងគា : ដល់ពេលអញ្ជឹងក៏ឈប់ទៅរៀនទៅ?

ហាន : ចា៎!

សេងគា : ហើយដល់ពេលអ៊ំឈប់រៀនហើយអ៊ំធ្វើអីទៀត?

ហាន : មានធ្វើអីទេ ធ្វើស្រែជាមួយម៉ែខ្ញុំ ។

សេងគា : ចុះឆ្នាំប៉ុន្មានទៅ បានអ៊ំទៅក្របេះ?

ហាន : ឆ្នាំប៉ុន្មានទេ អាយុ១៧ហើយបានទៅ ។

សេង៉គា ៖ ប៉ុន្តែមិនទាន់មាន លន់ ណុលមកទម្លាក់គ្រាប់បែកទេ?

ហាន ៖ នៅទេ កាលទៅហ្នឹងថាទៅលេង១ផ្ទះអ៊ំ ហើយខ្ញុំក៏នៅហ្នឹងទៅលេងទាំងម៉ែទាំងពុកហ្នឹង គាត់យកពុកក្រោយទៀត ថាទៅលេងដល់ទៅលេងទៅ ទៅបានប្រហែល១ខែដាំងគេ បិទកាណូត លន់ ណុលអីហ្នឹងទម្លាក់សម្តេច បិទកាណូតទៅក៏ម៉ោវិញអត់រួចក៏នៅហ្នឹង រហូតទៅ ។

សេង៉គា ៖ ជិះកាណូតទៅអ៊ំ?

ហាន ៖ ចាំ!នៅហ្នឹងរហូតទៅ ។

សេង៉គា ៖ នៅខេត្តក្រចេះនៅភូមិអីគេអ៊ំ?

ហាន ៖ ភូមិក្រហមករ ។

សេង៉គា ៖ ភូមិក្រហមករ ឃុំ?

ហាន ៖ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ ។

សេង៉គា ៖ បាទ!អ៊ំនៅហ្នឹងដោយសារមូលហេតុអីគេ?

ហាន ៖ ខ្ញុំម៉ោហ្នឹងដោយសារកូនវានៅហ្នឹង១ ។

សេង៉គា ៖ អ៊ូ!កាលដែលនៅព្រែកប្រសព្វនោះ នៅក្រចេះ?

ហាន ៖ ថាម៉ោលេង១ទៅវិញអត់រួច បិទកាណូត ។

សេង៉គា ៖ អ៊ូ!គេទម្លាក់គ្រាប់បែកទៅក៏នៅហ្នឹងរហូតទៅ?

ហាន ៖ ចាំ!

សេង៉គា ៖ ម៉ែឪ ឪពុកម្តាយក៏នៅហ្នឹងដែរ?

ហាន ៖ ចាំ!

សេង៉គា ៖ ឪពុកម៉ោជាមួយទេ?

ហាន ៖ ម៉ោ ។

សេង៉គា ៖ ម៉ោដែរ ត្រូវគ្នាវិញហើយជាមួយម្តាយ?

ហាន ៖ អត់ទេ!គាត់យកប្តីក្រោយទៀត យកប្តីក្រោយទៀតម៉ោទាំងអស់គ្នាថាម៉ោលេង ។

សេង៉គា ៖ ប្តីគាត់ក្រោយទៀតឈ្មោះអីអ៊ំ?

ហាន ៖ ឈ្មោះ ឡាច ។

សេង៉គា ៖ ស្អីឡាចអ៊ំ?

ហាន ៖ យា ឡាច ទៅវិញអត់រួចទៅក៏នៅហ្នឹងរហូតទៅ ។

សេងគា ៖ ចុះកាលនៅហ្នឹងនៅទាំងអស់គ្នា ឪពុកចុងក៏នៅដែរ?

ហាន ៖ ចា៎!

សេងគា ៖ ដល់នៅហ្នឹងបានឆ្នាំ អត់រត់ទៅណាទៀតអ៊ំ?

ហាន ៖ អត់ទេនៅតែហ្នឹងម៉ង នៅតែហ្នឹងដល់ពេលលន់ ណុល ចូលទៅហ្នឹងអី ។

សេងគា ៖ អ៊ំរៀបការពីឆ្នាំប៉ុន្មានអញ្ចឹង រៀបការអាយុប៉ុន្មាន?

ហាន ៖ រៀបការអាយុ១៨ ។

សេងគា ៖ អ៊ំរៀបការអាយុ១៨ឆ្នាំ កាលហ្នឹងសម័យលន់ ណុលឬក៏ពេលលន់ណុលហើយឬក៏ ពេលប៉ុល ពត ពេលខ្មែរក្រហម?

ហាន ៖ កាលហ្នឹងការបណ្តើរគេដេញចាប់ទាហានបណ្តើរកាលហ្នឹង ។

សេងគា ៖ អ៊ូ!កាលហ្នឹងលន់ ណុល ប្រហែល៧០ជាង?

ហាន ៖ ចា៎!គេដើរចាប់ប្រុសៗ ។

សេងគា ៖ ប្រហែល៧៣-៧៤ហើយអ៊ំ?

ហាន ៖ ចា៎!ដើរចាប់យកធ្វើទាហាន ឲ្យពួកប្រុសៗរត់ទៅដេកនៅក្នុងព្រៃហ្នឹង ។

សេងគា ៖ ការម៉ែឪគាត់រៀបចំឲ្យអ៊ំ?

ហាន ៖ ចា៎!

សេងគា ៖ ប្តីគាត់អ្នកស្រុកណាអ៊ំ?

ហាន ៖ នៅក្របេះហ្នឹង

សេងគា ៖ នៅក្របេះកាលហ្នឹងគាត់ធ្វើគ្រូដែរអ៊ំ?

ហាន ៖ ចា៎!

សេងគា ៖ គេធ្វើគ្រូដែលអញ្ចឹង ពេលសម័យប៉ុល ពតគេអត់ធ្វើបាប?

ហាន ៖ គ្រូជំនាន់នេះហ្នឹង ។

សេងគា ៖ ជំនាន់ក្រោយ?

ហាន ៖ ដែលជំនាន់កំពុងពីសង្គមមុននៅរៀន ដល់ពេលជំនាន់នេះម៉ោគេចាត់តាំងឲ្យបង្រៀន រហូតជាង២០ឆ្នាំហើយ ។

សេងគា ៖ អ៊ូ!អញ្ចឹង ហើយដល់ពេលសម័យទម្លាក់គ្រាប់បែកអ៊ំអត់ទៅណាទេ នៅហ្នឹងរហូត?

ហាន ៖ អត់ទៅណាទេ ។

សេងគា ៖ អត់មានស្ថានភាពប្រែប្រួលអីទេនៅកន្លែងហ្នឹង?

ហាន ៖ អត់ទេ កន្លែងហ្នឹងដូចស្រួលដែរ ទម្លាក់គុងក្តាំងៗមែន ប៉ុនដូចខាងឆ្វេង ខាងក្រចេះអី ទម្លាក់មើលទៅឃើញប៉ុនក្រោយខ្ញុំនៅហ្នឹងអី ខាងក្រោយៗព្រៃទម្លាក់តិចៗប៉ុនកន្លែង ហ្នឹងដូចសុខសប្បាយដែរ ដូចអត់មានរត់ទៅណាទេ អត់មានជម្លៀសទៅណាទេ ។

សេងគា ៖ ដល់អញ្ចឹងទៅអ៊ីក៏នៅហ្នឹងរហូតទៅ ទាំងប្តី?

ហាន ៖ ចា៎!

សេងគា ៖ នៅជាមួយគ្នាបានកូនប៉ុន្មានហើយកាលហ្នឹង ពេលទម្លាក់គ្រាប់បែកហ្នឹង?

ហាន ៖ បាន៤-៥នាក់ហើយហ្នឹង ។

សេងគា ៖ កូនកើតទាន់សម័យប៉ុល ពត ទាំងអស់ឬអត់ទេ ឬក៏ទាន់ខ្លះអត់ទាន់ខ្លះ?

ហាន ៖ ជិតទាន់ហ្នឹងទាំងអស់ហ្នឹងគិតទៅ ។

សេងគា ៖ កូនច្បងគេអាយុប៉ុន្មានហើយឥឡូវ?

ហាន ៖ កូនច្បងអាយុ៣០ជាងហើយ ចូល៤០ហើយ ។

សេងគា ៖ ចុះកូនពៅ?

ហាន ៖ កូនពៅ១៨ ។

សេងគា ៖ អ៊ូ!១៨អត់ទាន់ខ្មែរក្រហមអីទេ?

ហាន ៖ ចប់ហើយ ។

សេងគា ៖ អញ្ចឹងប្រហែលទាន់បាន៤-៥នាក់?

ហាន ៖ ចា៎!ចប់ហើយប្រហែលបាន៣-៤-៥នាក់មែនហ្នឹង ។

សេងគា ៖ តែកូនអីកាលហ្នឹង ចុះចូលដល់សម័យ៧៥ ប៉ុល ពតនោះមានរត់ទៅណា?

ហាន ៖ អត់មានផង ។

សេងគា ៖ នៅហ្នឹងទៀត?

ហាន ៖ ចា៎!

សេងគា ៖ ហើយហូបចុកអីម៉េចដែរអ៊ំ?

ហាន ៖ មានអីវាឆ្អែតខ្លះ មិនឆ្អែតខ្លះ ។

សេងគា ៖ មានបាយមានអីដែរអ៊ំ?

ហាន ៖ អត់ទេសុទ្ធតែបបរ កាលហ្នឹងបបររាវៗ ។

សេងគា ៖ ហើយកាលហ្នឹងពីគេប្រធានសហករណ៍អ៊ំ?

ហាន ៖ ប្រធានសហករណ៍ខ្ញុំភ្លេចអស់ហើយ ។

សេង៥ា ៖ មានចាំឈ្មោះទេអឺ?

ហាន ៖ ឈ្មោះអីៗទេច្រើនសឹងអី ។

សេង៥ា ៖ អត់មានចាំឈ្មោះម្នាក់ទេ?

ហាន ៖ ឈ្មោះ តាអឿន មួយ រួចហើយគេផ្លាស់ទៀត ។

សេង៥ា ៖ គាត់ជាមនុស្សម៉េចដែរអឺ តាអឿនហ្នឹង កាយឬស្លូត?

ហាន ៖ មើលទៅរាង៥ម្មតា ដូចមិនកាចណាស់ ដូចមិនស្លូតណាស់ ។

សេង៥ា ៖ នៅជាមួយតា អឿង អត់រត់ទៅខ្មែរក្រហមនៅហ្នឹង៥ាំង៣ឆ្នាំ ៧៩ម៉ង៥្លុមវៀតណាម ចូល?

ហាន ៖ ចាំ!អត់មានរត់ទៅណាទេ ។

សេង៥ា ៖ ហើយគេអត់ជម្លៀសទៅណាទេភូមិហ្នឹង?

ហាន ៖ អត់ទេ ។

សេង៥ា ៖ ទាំងអស់គ្នាម៉ង៥ប្រជាជននៅភូមិហ្នឹង?

ហាន ៖ ចាំ!ទាំងអស់គ្នា ។

សេង៥ា ៖ តែមានត្រីហូបបានជិតស្ទឹង?

ហាន ៖ ត្រីសំបូរ វាអត់តែបាយ ។

សេង៥ា ៖ អញ្ចឹងក៏គ្រាន់បើដែរ ខ្លះអត់មានអីហូប?

ហាន ៖ ត្រីទន្លេនៅចំពីមុខ ។

សេង៥ា ៖ ហើយចុះនៅហ្នឹងមានឃើញគេដឹកមនុស្សយកទៅកោះដ្លោងសម្លាប់ចោលច្រើនទេ?

ហាន ៖ អូយដឹកច្រើនណាស់ ។

សេង៥ា ៖ អឺឃើញដែរ?

ហាន ៖ ឃើញ ។

សេង៥ា ៖ នៅភូមិអឺអត់អីទេ?

ហាន ៖ ចាំ!អត់ទេនៅតែ២-៣ថ្ងៃទៀតត្រូវដល់ភូមិពួកខ្ញុំម្តង គេដឹកតាមភូមិៗ ។

សេង៥ា ៖ អូ!ពីភូមិណាម៉ោមុនអឺ?

ហាន ៖ ដឹកម៉ោតាំងពីលើៗម៉ោ ។

សេង៥ា ៖ ប៉ុន្តែភូមិអឺហ្នឹងនៅខាងក្រោយគេអីក៏ម៉េច?

ហាន ៖ ចា៎!ភូមិខ្ញុំហ្នឹងគេអត់ទាន់នេះទេ នៅតែ៣ថ្ងៃទៀតទេត្រូវគេដឹកយកទៅហើយគេឲ្យត្រៀមហើយហ្នឹង ។

សេងគា ៖ បាទ!

ហាន ៖ គេដឹកយកទៅសម្លាប់អត់ឆ្ងាយទៀត នៅវត្តប្រហែលខ្សែនហ្នឹង វត្តហ្នឹង ។

សេងគា ៖ វត្តឈ្មោះអីអ៊ំ?

ហាន ៖ គេហៅវត្តព្រែកស្វាយ អណ្តូង៣ អណ្តូងគេចាក់លូរស៊ុទ្ធតែជ្រៅៗ ហើយដឹកទាំងឡានៗយកទៅដល់វត្តហ្នឹង គេអត់ប្រាប់ថាយកទៅសម្លាប់ទេ គេថាយកទៅឲ្យនៅហ្នឹងម៉ាភូមិទៀតអីអញ្ចឹង ទៅដល់គេឲ្យនៅស្នាក់នៅវត្តហ្នឹង កាប់ជ្រូកកាប់គោឲ្យស៊ី ស៊ីទៅយប់ឡើង ប៉ុនមុននឹងវ៉ៃទម្លាក់អណ្តូងមេក្រូ៣-៤ ។

សេងគា ៖ នៅភូមិអីគេអ៊ំ នៅវត្ត វត្តអីគេ?

ហាន ៖ វត្តព្រែកស្វាយ ។

សេងគា ៖ ព្រែកស្វាយ?

ហាន ៖ ចា៎!

សេងគា ៖ នៅក្នុងភូមិអី ភូមិព្រែកស្វាយហ្នឹងដែរ វត្តហ្នឹង?

ហាន ៖ ឃុំតាម៉ៅដែរ ។

សេងគា ៖ ឃុំតាម៉ៅ?

ហាន ៖ ចា៎!ស្រុកព្រែកប្រសព្វដែរ ។

សេងគា ៖ ដល់ឃើញគេដឹកអញ្ចឹងអ៊ំភ័យឬទេ?

ហាន ៖ ភ័យ!ម្នាក់ៗឡើងរួញខ្លួនហើយនៅតែក្នុងផ្ទះអត់ហានចេញ ។

សេងគា ៖ កាលហ្នឹងជិតដាច់ហើយ ជិត៧៩ហើយអ៊ំ?

ហាន ៖ ចា៎!ជិតហើយ យកទៅយប់ឡើងចាក់មេក្រូត្រហឹងអត់ពុ្ធ តែគេនៅជិតហ្នឹងពុ្ធមនុស្សស្រែក វ៉ៃទម្លាក់ៗ ។

សេងគា ៖ មានអន្លង់៣អ៊ំ?

ហាន ៖ ចា៎!

សេងគា ៖ អន្លង់ធំៗទេអ៊ំ?

ហាន ៖ ធំៗជ្រៅ ។

សេងគា ៖ អ៊ំមានបានទៅមើលទេអ៊ំ?

ហាន ៖ ខ្ញុំអត់បានទៅទេ ប៉ុនអណ្ដូងហ្នឹងកាលខ្ញុំទៅវត្ត ខ្ញុំទៅមើលវាជ្រៅៗ ដល់ពេលគេវៃទម្លាក់ៗ ឡើងណែនពេញអណ្ដូង២-៣ហ្នឹង ។

សេងគា ៖ ទាល់ចប់ហើយ បានអ៊ំទៅមើលទៅបុណ្យ?

ហាន ៖ អត់ទេ!កាលខ្ញុំទៅមិនគេវៃហ្នឹង ខ្ញុំមើល ទៅវត្តអីទៅខ្ញុំមើលអណ្ដូងហ្នឹង ។

សេងគា ៖ អ្ហូ!ពេលសម័យហ្នឹងមានវត្តដែរអ៊ំ?

ហាន ៖ មាន ។

សេងគា ៖ គេឲ្យទៅវត្តដែលអ៊ំ?

ហាន ៖ វត្តហ្នឹងទៅមើលទៅលេងអីអញ្ចឹង ។

សេងគា ៖ អ្ហូ!ទៅលេងទេ មិនមែនទៅបុណ្យទេ?

ហាន ៖ ចា៎!ទៅលេងអីអញ្ចឹងទៅ នាំគ្នាលួចមើលអណ្ដូង ។

សេងគា ៖ ហើយឃើញអណ្ដូងហ្នឹងជ្រៅៗអ៊ំ អណ្ដូងហ្នឹងប្រហែលប៉ុន្មានម៉ែត្រទៅ?

ហាន ៖ អណ្ដូងហ្នឹងដាក់លូប្រហែល១២លូអីណា៎ ។

សេងគា ៖ អ្ហូ!វៃទម្លាក់ៗអ៊ំ?

ហាន ៖ ចា៎!វៃទម្លាក់ៗទាំងចាស់ទាំងក្មេង ហើយបងប្អូនជម្លៀសពីពេញទៅ ឲ្យទៅនៅភូមិ ឲ្យទៅនៅខាងខេត្តក្រចេះហ្នឹងតាមខេត្តតាមស្រុកហ្នឹងប្រមូលទៅវៃអស់ ។

សេងគា ៖ អញ្ចឹង!ភាគច្រើនមានឃើញពួកណា ពួកអ៊ីស្លាមឬពួកខ្មែរអ៊ំ?

ហាន ៖ ខ្លះខ្មែរខ្លះ ខ្លះចាមខ្លះ ។

សេងគា ៖ អញ្ចឹង?

ហាន ៖ ចា៎!

សេងគា ៖ ជិះកាណូតកាត់តាមមុខផ្ទះអ៊ំហ្នឹង?

ហាន ៖ ជិះកាណូតអី ដឹកឡានហ្នឹង ដឹកឡានទាំងឡានៗកាត់តាមផ្លូវផ្ទះខ្ញុំអញ្ចឹង ។

សេងគា ៖ ឡានទាហានពេញៗអ៊ំ?

ហាន ៖ ឡានទាហាន ឡានឃុបទៀតហ្នឹង ។

សេងគា ៖ អ្ហូ!គេមានដំណាក់គេចាប់ម៉ោដល់ជិតភូមិ ម៉េចបានអ៊ំដឹង៣ថ្ងៃទៀតដល់ភូមិអ៊ំ?

ហាន ៖ បើគេចេះតែ មេៗហ្នឹងគេយកគេអត់ថាយកទៅសម្លាប់ផង គេថាគេយកទៅឲ្យនៅភូមិថ្មីទៀតអញ្ចឹង ។

សេងគា ៖ ដល់យកទៅបាត់ៗអញ្ចឹង?

ហាន ៖ ចាំ!ប៉ុនយកទៅពួកហ្នឹងគេតាមដានមើលឃើញថាយកទៅដាក់នៅវត្ត ។

សេងគា ៖ ពួកណាតាមដានអ៊ំ?

ហាន ៖ ពួកភូមិហែរ ដូចថាភូមិហែរមួយជួរអញ្ចឹងទៅ ។

សេងគា ៖ ហើយដល់ពេលសម្ងាប់សាកសពហើយអ៊ំមានឃើញទេ នៅក្នុងអណ្តូងហ្នឹង?

ហាន ៖ ពួកហ្នឹងគេទៅមើល ខ្ញុំអត់ហានទៅ ។

សេងគា ៖ អត់ហានទៅទេ ចុះពួកណាទៅ?

ហាន ៖ ពួកស្រុកខ្ញុំស្រុកភូមិខ្ញុំ ។

សេងគា ៖ ឈ្មោះអីគេអ៊ំ អ្នកដែលទៅប្រាប់អ៊ំហ្នឹង?

ហាន ៖ ពួកដែលគេទៅមើល ។

សេងគា ៖ អ៊ំអត់មានចាំឈ្មោះទេ ឈ្មោះអីខ្លះអ៊ំ?

ហាន ៖ ឈ្មោះ ដាន ឈ្មោះវី ពួកហ្នឹងនាំគ្នាទៅមើល ។

សេងគា ៖ អាហ្នឹងដឹករាល់ថ្ងៃម៉ងអ៊ំ កាលហ្នឹង អាជិតបែកហ្នឹងអត់ដឹកទេ ពីមុនអត់អីទេ?

ហាន ៖ អាជិត ហ្នឹងហើយដូចថានៅក្នុង១០ថ្ងៃហ្នឹងបែកហ្នឹង ប៉ុន្មានយប់ហ្នឹងដឹករាល់តែយប់ ម៉ង ។

សេងគា ៖ ដល់ពេលអ៊ំនៅហ្នឹងបែក ដល់ពេលនេះទៅបែកអ៊ំ?

ហាន ៖ ចាំ!ហើយពួកខ្ញុំគេថាត្រៀម គេប្រជុំឲ្យត្រៀមខ្លួនគេផ្លាស់ទីលំនៅទៅនៅភូមិថ្មីទៀត អញ្ចឹង នៅតែ៣ថ្ងៃទៀតគេយកទៅ ហើយទទួលបែកទៅបាននាំគ្នាអរវិញ ។

សេងគា ៖ បាទ!ដល់ពេលបែកទៅ ហើយប្តីអ៊ំអីនៅជុំគ្នាអត់ទៅណាទេ?

ហាន ៖ នៅទាំងអស់គ្នាហ្នឹង បង្រៀនក្មេង ។

សេងគា ៖ នៅបង្រៀនក្មេងហ្នឹងទៀត?

ហាន ៖ ចាំ!នៅបង្រៀនរាល់ថ្ងៃហ្នឹង គេឲ្យបង្រៀនជំនាន់វៀតណាមហើយហ្នឹង គេឲ្យបង្រៀននៅ សាលាជិតផ្ទះដែរ ។

សេងគា ៖ បង្រៀនកូនខ្មែរក្រហម ឬកូនអ្នកស្រុកអ្នកភូមិធម្មតាទេ?

ហាន ៖ កូនអ្នកស្រុកអ្នកភូមិយើងហ្នឹង ។

សេងគា ៖ លួចបង្រៀនអ៊ំ?

ហាន ៖ កាលហ្នឹងបង្រៀនដូចអត់លួចទេ គេឲ្យបង្រៀនម៉ង ។

សេងគា ៖ អញ្ចឹង?

ហាន ៖ ចាំ!

សេង៍គា ៖ ខ្មែរក្រហមគេអត់ឲ្យបង្រៀនអីទេ ឬបង្រៀនតែកូនកម្មាភិបាលទេ ឬក៏ផុតខ្មែរក្រហមហើយ ដល់ពេលយួនចូលហើយបានបង្រៀន?

ហាន ៖ នៅវៃគ្នាខ្វះអីខ្វះគ្រាន់តែថា ។

សេង៍គា ៖ ប៉ុន្តែយួនចូលហើយៗ ?

ហាន ៖ ចា៎!

សេង៍គា ៖ បានគេឲ្យបង្រៀនអុី?

ហាន ៖ ចា៎!

សេង៍គា ៖ ហើយប្អូនអុីនេះអត់អីទេ នៅរស់សព្វថ្ងៃទេ ។

ហាន ៖ អត់អីទេ ។

សេង៍គា ៖ ឪពុកម្តាយក្មេងហ្នឹងនៅរស់ទេ កាលហ្នឹងអត់មានអីទេ ម៉ាភូមិហ្នឹងការពិតអត់អីទាំងអស់អុី?

ហាន ៖ ភូមិហ្នឹងភាគច្រើនម៉ាផ្ទះមួយ ម៉ាផ្ទះពីរផ្ទះមួយច្រើនចូលទៅកង៍ទ័ពៗដូចថាគេថាសម័យបដិវត្តន៍ មួយចូលពីរចូលច្រើនចូលគ្រប់ផ្ទះ កាលហ្នឹងកូនក្រមុំកំលោះច្រើនតែចូលទៅ ដូចខ្ញុំកាលហ្នឹងកូននៅតូចៗអត់ចូលអត់អីទេ កូនតូច ។

សេង៍គា ៖ ហើយកាលហ្នឹងពេលឈឺណេលអីមានពេទ្យគេមើលត្រឹមត្រូវទេអុី?

ហាន ៖ ពេទ្យដូចមិន មានដែរប៉ុនសុំថ្នាំយកមកឲ្យលេបអីដូចថ្នាំតែមួយមុខៗ អត់មានអីប្លែកសោះ ។

សេង៍គា ៖ ថ្នាំអីគេអុី?

ហាន ៖ ជំនាន់ហ្នឹង ។

សេង៍គា ៖ ថ្នាំអាចម៍ទន្សាយអុី?

ហាន ៖ ចា៎ថ្នាំហ្នឹងទៅសុំនោះ ។

សេង៍គា ៖ ចុះដល់ពេលបែកអញ្ចឹងតាជឿនអីមានស្លាប់មានអីឬនៅ ឬក៏នៅរស់សព្វថ្ងៃទេ?

ហាន ៖ តាជឿន?

សេង៍គា ៖ តាអឿនអីហ្នឹង?

ហាន ៖ តាអឿនដល់ពេលចប់ទៅ គេយកទៅសម្លាប់ចោលដែល ។

សេង៍គា ៖ អ្នកណាគេអ្នកយកទៅអុី?

ហាន ៖ មេគេធំទៀត ផ្សេងទៀតមិនដឹងពីណាខ្ញុំអត់ស្គាល់ដែរ ។

សេងគា ៖ អត់ផងដែរ ម៉េចបានយកគាត់ទៅសម្លាប់គាត់ស្លូតដែរអ៊ំ?

ហាន ៖ គាត់មិនកាចណាស់ណា៎ ។

សេងគា ៖ ប៉ុន្តែអត់ដែលធ្វើបាបអ្នកភូមិទេ?

ហាន ៖ ដូចអត់ដែលផង ។

សេងគា ៖ អត់ដែលឃើញទេអ៊ំ?

ហាន ៖ ចា៎!

សេងគា ៖ មិនមែនអ្នកភូមិគេតាមចាប់យកទៅទេ?

ហាន ៖ អត់ទេ ដូចថាគេមោ៉ពីស្រុកមោ៉ពីខេត្តអីណា ។

សេងគា ៖ ហើយអ៊ំនៅហ្នឹងរហូតតាំងពីបែក ហើយប្តីបង្រៀននៅហ្នឹងរហូតដែរអ៊ំ?

ហាន ៖ ចា៎!

សេងគា ៖ ដល់មោ៉នៅនេះឆ្នាំណាអ៊ំ?

ហាន ៖ ឆ្នាំណាទេ ។

សេងគា ៖ មោ៉បានប៉ុន្មានហើយ មោ៉នៅនេះ?

ហាន ៖ ខ្ញុំមោ៉បាន៨ឆ្នាំហើយ ។

សេងគា ៖ ៨ឆ្នាំ អញ្ចឹងមានន័យថាមោ៉នៅឆ្នាំ២០០៣ណាស់អ៊ំ?

ហាន ៖ ហ្នឹងហើយបែបអញ្ចឹង ។

សេងគា ៖ ឆ្នាំ២០០៣ហ្នឹងមោ៉នៅនេះទេ មោ៉ទាំងប្តីទាំងកូនអញ្ចឹងទៅ?

ហាន ៖ មោ៉ទាំងអស់គ្នា ។

សេងគា ៖ ម៉េចបានមោ៉នៅនេះវិញអ៊ំ?

ហាន ៖ កូនខ្ញុំវាមោ៉នៅនេះមុន ហើយវាគេហៅ ។

សេងគា ៖ កូនអ៊ំមោ៉ពីពេលណាមោ៉?

ហាន ៖ កូនខ្ញុំមោ៉ប្រហែលជាមួយឆ្នាំមុន ។

សេងគា ៖ អ្ហូ!គាត់មោ៉ធ្វើអីអ៊ំ?

ហាន ៖ វាមោ៉រកស៊ីហ្នឹង ។

សេងគា ៖ អញ្ចឹងហើយក៏អ៊ំមោ៉តាមទៅ?

ហាន ៖ ហើយដល់នេះវាគេហៅ ថាម៉ែអើយមោ៉នេះដីច្រើនណាស់ ។

សេងគា ៖ មោ៉ចាប់ដីចាប់អីគេទៅ?

ហាន ៖ ចា៎! ហើយក៏ប្រមូលតាមវាទៅ ។

សេងគា ៖ ម៉ោចាប់ដីបានច្រើនទេអ៊ី?

ហាន ៖ អត់បានចាប់ផង ទិញគេម៉ង ទិញគេបាន៣-៤ហត្ថ ក្រោយផ្ទះធ្វើចំការ ម៉ោដល់គេចាប់អស់ហើយហ្នឹង គេអ្នកម៉ោមុនគេចាប់អស់ ។

សេងគា ៖ បាទ! អ៊ីដូចជាអស់សំនួរចង់សួរអ៊ីហើយ ចុងក្រោយចង់សួរអ៊ីបន្តិច នៅពេលមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមអញ្ចឹងអ៊ីមានអារម្មណ៍ម៉េចដែរអ៊ី អ៊ីយល់យ៉ាងម៉េច ដែរអ៊ីខឹងសម្បារនឹងគេកាត់ទោសអញ្ចឹងទេឬអត់ទេ?

ហាន ៖ កាត់ទោសម៉េច កាត់ខ្មែរក្រហម?

សេងគា ៖ កាត់មេដឹកនាំធំៗ ដូចអ្នកដឹងនាំប្រទេសអញ្ចឹង ឲ្យគេចូលព្រៃវេទនាសម្លាប់មនុស្សអ៊ីអញ្ចឹងគេកាត់តែមេធំៗទេ ចុះអ៊ីយល់យ៉ាងម៉េចដែរពេលដែលមានអញ្ចឹង?

ហាន ៖ គ្មានយល់យ៉ាងម៉េច បើគេកាត់អីកាត់ទៅ ។

សេងគា ៖ អញ្ចឹង?

ហាន ៖ ចា៎!

សេងគា ៖ អ៊ីចង់ឲ្យគេកាត់អញ្ចឹងដែរ?

ហាន ៖ ចា៎! ព្រោះធ្វើបាបកាលហ្នឹង ធ្វើបាបប្រជាជន ។

សេងគា ៖ អ៊ីអត់មានគិតថាគាត់ធ្វើអីទេ អត់ទេ?

ហាន ៖ ចា៎!

សេងគា ៖ តាមច្បាប់អ៊ី?

ហាន ៖ ចា៎!

សេងគា ៖ អញ្ចឹងចុងក្រោយអ៊ីមានពាក្យអីចង់សួរនាំឬចង់និយាយអីបន្ថែមទៀតទេអ៊ី ដែលខ្ញុំមិនទាន់បានសួរអ៊ីអញ្ចឹង?

ហាន ៖ មិនដឹងបន្ថែមម៉េចខ្ញុំអត់ចេះនិយាយផង ។

សេងគា ៖ ហើយអ៊ីមានស្គាល់តាអានតាអីទេ?

ហាន ៖ តាអានណា?

សេងគា ៖ តាអានលក់ថ្នាំលក់អី?

ហាន ៖ អូ! ស្គាល់ ។

សេងគា ៖ បាទ! ហើយគាត់មនុស្សម៉េចដែរ គាត់ធ្វើបុណ្យធ្វើទានណាស់ឥឡូវ?

ហាន ៖ មានអីគាត់ដូចស្ពូត ដូចអត់មានផង ។

សេងគា ៖ បាទ!អញ្ចឹងអត់អីទេ ហើយខ្ញុំមានតែប៉ុណ្ណឹងខ្ញុំចង់សួរអ៊ំ ថ្ងៃនេះថ្ងៃទី១៩ខែ៣ ឆ្នាំ ២០១១ ។ បាទ!អញ្ចឹងខ្ញុំជំរាបលាអ៊ំ ។

ហាន ៖ ចា៎!

សេងគា ៖ អរគុណច្រើន! ។

**ចប់**